雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.170

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី26 លេខ7768 ថ្ងៃសុក្រ ទី26 ខែតុលា ឆ្នាំ 2018


## ទិវាថ្មីរបស់ជនជាតិចិន: ទិវាប្រមូលផលរបស់កសិករចិន



*កម្មវិធីសម្តែងសិល្បៈ "ពិធី បន់ស្រន់នៅពេលប្រមូលផល" ត្រូវសម្តែងជាលើកទី១ នៅឃុំប៉ាប៉ាវ ស្រុក ក្វាងណាន ខេត្តយូណាន (រូបថតដោយ ឈីន ហ្វី)*

ពេលថ្មីៗនេះ មជ្ឈិមបក្សកុម្មុយនិស្តចិន និងក្រុមប្រឹក្សាកិច្ចការរដ្ឋចិន បានអនុញ្ញាតឱ្យកំណត់យកថ្ងៃរដូវកាល "ឈីវហ្វឹន" រាល់ឆ្នាំជា "ទិវាប្រមូលផលរបស់កសិករ" ចិន តាំងពីឆ្នាំ ២០១៨តទៅ ។ នេះជាលើកទី១ ដែលប្រជាកសិករចិនមានទិវារបស់ខ្លួនតាំងពីសម័យបុរាណរហូតដល់សព្វថ្ងៃ ។

លោកបណ្ឌិត្យសភាចារ្យ យាន់ឡុងភីង បានមានប្រសាសន៍ថា រឿងដែលកសិករប្រមូលបានផលច្រើន គឺជារឿងដែលខ្ញុំសប្បាយចិត្តបំផុត ។ ការប្រមូលបានផលច្រើនជាការឆ្លើយតបទៅនឹងកិច្ចឧស្សាហ៍ព្យាយាមរបស់កសិករ ដូច្នេះការបង្កើតទិវានេះគឺជារឿងដែលធ្វើឱ្យសង្គមទាំងមូលសប្បាយចិត្តយ៉ាងខ្លាំង ។

លោក សុង ហ្វូ លេខាបក្សភូមិក្វាងហ្វូតុងជាខណ្ឌយ៉ុងនាន ខេត្តហ៊ឺប៉េ ធ្លាប់បានលើកសំណើឱ្យបង្កើត "ទិវាកសិករចិន" ៥ លើកហើយ ។ សព្វថ្ងៃលោកបានសម្រេចសុបិនរបស់ខ្លួន ហើយធ្វើឱ្យប្រជាកសិករចិនរាប់រយលាននាក់មានទិវារបស់ខ្លួន ។ ការបង្កើតទិវាប្រមូលផលរបស់កសិករចិនបានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាកសិករចិន ។ ទិវាដ៏សំខាន់នេះនឹងអាចធ្វើឱ្យគេចងចាំឱ្យបានច្បាស់នូវស្រែចម្ការ កសិករ និងកសិដ្ឋានដែលផ្តល់កសិផលដល់ពួកយើងជារៀងរហូតមក ។

លោក អ៊ូ សៀអឺន លេខាបក្សនៃភូមិហ្វាស៊ី ក្រុងជាំងយីន ខេត្តជាំងស៊ូ បានបញ្ជាក់ថា ការបង្កើត "ទិវាប្រមូលផលរបស់កសិករចិន" មិនគ្រាន់តែជាការគោរព និងការវាយតម្លៃខ្ពស់ចំពោះប្រជាកសិករប៉ុណ្ណោះទេ ហើយក៏បានបង្ហាញពីការយកចិត្តទុកដាក់ និងការគាំទ្រចំពោះប្រជាកសិករ ព្រមទាំងជាការលើកទឹកចិត្តចំពោះពួកគេ ។

ការបង្កើត "ទិវាប្រមូលផលរបស់កសិករចិន" មិនគ្រាន់តែបានលើកទឹកចិត្តដល់ប្រជាកសិករប៉ុណ្ណោះទេ ហើយបានទទួលការចាប់អារម្មណ៍ពីសំណាក់ប្រជាជនដែលរស់នៅក្នុងទីក្រុងផងដែរ ។ អ្នកក្រុងខ្លះបានបញ្ចេញយោបល់តាមអ៊ីនធឺណេតថា យើងនឹងទៅចូលរួមអបអរសាទរទិវានេះ ! លេងក្នុងទីក្រុងមិនសប្បាយទេ ខ្ញុំចង់ទៅលេងតំបន់ជនបទ ។ ទោះជាសម្រាកឬអត់ ខ្ញុំត្រូវទៅដើរលេងតំបន់ជនបទម្តង ។ ក្នុងឱកាសទិវាប្រមូលផលនេះ ប្រជាជនដែលរស់នៅក្នុងទីក្រុងនឹងទៅមើលទេសភាពតំបន់ជនបទ រួមគ្នាអបអរសាទរទិវានេះ ជាមួយប្រជាកសិករ ដើម្បីធ្វើឱ្យទិវានេះកាន់តែមានឈ្មោះល្បីល្បាញ និងជំរុញការធ្វើសមាហរណកម្មទីក្រុង និងជនបទ ៕



*អ្នកស្រុកកំពុងនេសាទត្រី នៅលើបឹងទានឈីនៃខេត្តយូណាន (រូបថតដោយ យ៉ាង ជឹង)*

## ព័ត៌មានភ្ជាប់នឹងរូបភាពចម្រៀង និងរបាំយូណានបង្ហាញភាពត្រចះត្រចង់នៅក្រុងគែរ

ពេលថ្មីៗនេះ រាត្រីសមោសរ "ចែករំលែកគ្នាអំពីចម្រៀង និងរបាំយូណាន" បានត្រូវរៀបចំនៅសាលសម្តែងនៃមជ្ឈមណ្ឌលវប្បធម៌ចិនក្នុងរដ្ឋធានីគែរប្រទេសអេហ្ស៊ីប ៕

**ដោយ មុឹង ថាវ (ស៊ីនហួ ចិន)**



*តួសម្តែងនៃក្រុមសិល្បៈ និងវប្បធម៌ខេត្តយូណានកំពុងសម្តែងរបាំជនជាតិតៃ "ក្ងោកមាស" (រូបថត ដោយ មុឹង ថាវ )*

## រូបមន្ត "R2R" សម្រេចនូវការទូទាត់ដោយតម្លាភាពក្នុងដំណើរទេសចរណ៍ទាំងស្រុង

ពេលថ្មីៗនេះ រូបមន្ត "R2R" របស់ក្រុមហ៊ុនជុងហឺថៃស៊ីន បានត្រូវដាក់តាំងបង្ហាញជាផ្លូវការនៅចំពោះមុខប្រព័ន្ធផ្សព្វផ្សាយ ។ រូបមន្តនេះជាប្រព័ន្ធមួយក្នុងកម្មវិធី APP "ដើរលេងខេត្តយូណាន ដោយប្រើទូរស័ព្ទតែមួយគ្រឿង" ។ លោក ជូ ប៉ៃវ៉ៃ ប្រធានសមាគមទីភ្នាក់ងារទេសចរណ៍ក្រុងគុនមីង និងជាទេសាភិបាលរងនៃក្រុមហ៊ុនជុងហឺថៃស៊ីន ខេត្តយូណាន បានបញ្ជាក់ថា រូបមន្ត "R2R" នេះនឹងអាចសម្រេចបាននូវការទូទាត់បង់ថ្លៃសេវាកម្មទេសចរណ៍ផ្សេងៗតាមរយៈកម្មវិធី APP "ដើរលេងខេត្តយូណាន ដោយប្រើទូរស័ព្ទតែមួយគ្រឿង" ដែលបានគ្របដណ្តប់លើការចុះកិច្ចសន្យា ការកំណត់កម្មវិធីដើរលេង ការបង់ថ្លៃសណ្ឋាគារ មគ្គុទ្ទេសក៍ ភោជនីយដ្ឋាន និងសំបុត្រចូលរមណីយដ្ឋានទេសចរណ៍ជាដើម ។ រូបមន្តនេះ ជាប្រព័ន្ធថ្មីមួយ ដែលអាចវាយតម្លៃជាសាធារណៈ និងទទួលការពិនិត្យតាមដានពីរដ្ឋាភិបាល ដែលនឹងអាចជំរុញការអភិវឌ្ឍធនធានទេសចរណ៍ឱ្យកាន់តែស៊ីជម្រៅ និងទទួលការរីកចម្រើនកាន់តែឆាប់រហ័ស៕ **ដោយចាំង ហ្វាង**

## ពិព័រណ៍សហប្រតិបត្តិការទន្លេឡានឆាង-មេគង្គ បើកពិព័រណ៍នៅ ថ្ងៃទី២៣ខែវិច្ឆិកា ក្នុងក្រុងគុនមីង

តាមប្រភពព័ត៌មានពីសន្និសីទសារព័ត៌មានដែលការិយាល័យព័ត៌មាននៃសាលារដ្ឋបាលខេត្ត យូណាន រៀបចំនៅថ្ងៃទី២៥ ខែកញ្ញានោះបានឱ្យដឹងថា ពិព័រណ៍សហប្រតិបត្តិការទន្លេឡានឆាង-មេគង្គឆ្នាំ ២០១៨ នឹងបើកពិព័រណ៍នៅថ្ងៃទី២៣ ខែវិច្ឆិកា ក្នុងក្រុងគុនមីង នៃខេត្ត យូណាន ។

ពិព័រណ៍នេះ រៀបចំដោយសភាពាណិជ្ជកម្មអន្តរជាតិប្រទេសចិន និងទទួលបន្ទុកអនុវត្តន៍ជាក់ស្តែងដោយសាលារដ្ឋបាលក្រុងគុនមីង និងសមាគមជំរុញពាណិជ្ជកម្មខេត្តយូណាន (សភាពាណិជ្ជកម្មអន្តរជាតិខេត្តយូណាន) ជាដើម ។

ពិព័រណ៍នេះរួមមាន សកម្មភាពសំខាន់បី គឺ "ពិព័រណ៍មួយ" "វេទិកាមួយ" និង" កិច្ចប្រជុំមួយ) ។

"ពិព័រណ៍មួយ" គឺពិព័រណ៍ផលិតផលសំខាន់ៗនៃបណ្តាប្រទេសនានា ដែលនឹងរៀបចំនៅមជ្ឈមណ្ឌលសន្និសីទ និងពិព័រណ៍អន្តរជាតិក្រុងគុនមីង ក្នុងអំឡុងពេលពីថ្ងៃទី២៣ ដល់ទី២៧ ខែវិច្ឆិកា ។ សហគ្រាសប្រទេសទន្លេឡានឆាងមេគង្គ ជប៉ុន កូរ៉េខាងត្បូង ទ្វីបអាហ្វ្រិក និងអឺរ៉ុបជាដើមនឹងចូលរួមក្នុងពិព័រណ៍នេះ ។ ពិព័រណ៍នេះរួមមានពន្លាពិព័រណ៍ចំនួនប្រាំពីរ គឺពន្លាពិព័រណ៍សមិទ្ធផលសហប្រតិបត្តិការឡានឆាង-មេគង្គ ពន្លាពិព័រណ៍ប្រទេសទន្លេឡានឆាង-មេគង្គ ពន្លាពិព័រណ៍ថាមពល និងផលិតផលពិសេស និងពន្លាពិព័រណ៍ឈើទាល និងសិប្បកម្មចម្លាក់ឈើជាដើម ។

"វេទិកាមួយ" គឺវេទិកាសហប្រតិបត្តិការបឹងទានឈី លើកទី៣ដែលនឹងរៀបចំនៅមជ្ឈមណ្ឌលសន្និសីទ និងពិព័រណ៍អន្តរជាតិក្រុងគុនមីង ក្នុងអំឡុងពេលពីថ្ងៃទី២៣ ដល់ ទី២៤ ខែវិច្ឆិកា ។

"កិច្ចប្រជុំមួយ" គឺកិច្ចប្រជុំសហប្រតិបត្តិការសហគ្រិនតំបន់ទន្លេឡានឆាង-មេគង្គ ដែលនឹងរៀបចំនៅមជ្ឈមណ្ឌលសន្និសីទ និងពិព័រណ៍អន្តរជាតិក្រុងគុនមីង ក្នុងអំឡុងពេលពីថ្ងៃទី២២ដល់ទី២៣ ខែវិច្ឆិកា ៕

**ដោយ លីវ ជឺយូ**

## ធ្វើជាមិត្តល្អគួរឱ្យជឿទុកចិត្តរបស់ប្រទេសកំពុងអភិវឌ្ឍន៍ជានិច្ច

**ដោយ ចា សៀវតុង**

ប្រទេសចិនជាប្រទេសកំពុងអភិវឌ្ឍន៍មួយ ។ បទពិសោធន៍ចិនគឺប្រទេសកំពុងអភិវឌ្ឍន៍ត្រូវតែខិតខំធ្វើការអភិវឌ្ឍ ។ ប៉ុន្មានឆ្នាំមកនេះប្រទេសចិនបានទទួលការរីកចម្រើនយ៉ាងឆាប់រហ័ស ជាពិសេសសព្វថ្ងៃប្រទេសចិនបានឈានចូលក្នុងដំណាក់កាលនៃការធ្វើកំណែទម្រង់ឱ្យកាន់តែស៊ីជម្រៅ ហើយកំពុងជួបនឹងបញ្ហាប្រឈមដ៏ច្រើនលើពិភពលោក ។ ប្រទេសកំពុងអភិវឌ្ឍន៍ដ៏ច្រើនកំពុងតែខិតខំសិក្សាស្រាវជ្រាវអំពីមាគ៌ាអភិវឌ្ឍន៍ដោយមានស្ថិរភាព ហើយត្រូវដោះស្រាយបញ្ហាប្រឈមផ្សេងៗ ។ ប្រទេសចិន និងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នានាមានផលប្រយោជន៍រួម និង គោលជំហរស្រដៀងគ្នាក្នុងការរក្សា សន្តិភាព ស្ថិរភាពនិងជំរុញការ អភិវឌ្ឍ។ ជារៀងរហូតមកប្រទេសចិនចាត់ទុកប្រទេសកំពុងអភិវឌ្ឍន៍ជាមូលដ្ឋានគ្រឹះនៃគោលនយោបាយទំនាក់ទំនងការទូតរបស់ប្រទេសចិន ។ ប្រទេសចិនយកចិត្តទុកដាក់កម្រិតខ្ពស់ចំពោះការអភិវឌ្ឍទំនាក់ទំនងជាមួយប្រទេសកំពុងអភិវឌ្ឍន៍ ហើយផ្តួចផ្តើមយ៉ាងសកម្មនិងគាំទ្រយ៉ាងពេញទំហឹងដល់ការធ្វើកិច្ចសហប្រតិបត្តិការរវាងប្រទេសកំពុងអភិវឌ្ឍន៍ ។

ការអនុវត្តជាក់ស្តែងបានសបញ្ជាក់ថា ការបង្កើនសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសកំពុងអភិវឌ្ឍន៍ជាជម្រើសយុទ្ធសាស្ត្រផ្នែកទំនាក់ទំនងការទូត ដែលប្រទេសចិនប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់ក្នុងរយៈពេលយ៉ាងយូរវែងកន្លងទៅ ។ ឆ្នាំនេះប្រទេសចិនបានទទួលសមិទ្ធផលថ្មីក្នុងវិស័យនេះ ។ ប្រទេសចិនបានរៀបចំដោយជោគជ័យនូវសកម្មភាពផ្សេងៗ ដែលបានបង្កើតយន្តការសន្ទនា និងសហប្រតិបត្តិការជាមួយប្រទេសកំពុងអភិវឌ្ឍន៍ក្នុងតំបន់នានា ដូចជាកិច្ចប្រជុំរដ្ឋមន្ត្រីលើកទី២នៃវេទិកាចិន-អាម៉េរិកឡាទីន កិច្ចប្រជុំរដ្ឋមន្ត្រីលើកទី៨ នៃវេទិកាសហប្រតិបត្តិការចិន-អារ៉ាប់ និងកិច្ចប្រជុំកំពូលក្រុងប៉េកាំងនៃវេទិកាចិន-អាហ្វ្រិក ព្រមទាំងកិច្ចប្រជុំកំពូលស្តីពីការអបអរសាទរខួបលើកទី១៥ នៃការបង្កើតទំនាក់ទំនងភាពជាដៃគូយុទ្ធសាស្ត្រចិន-អាស៊ាន ដែលនឹងរៀបចំនៅខែវិច្ឆិកាខាងមុខ ។ ក្រៅពីនេះ ភាគីចិនបានរៀបចំសកម្មភាពទំនាក់ទំនងការទូតសំខាន់ៗជាច្រើន ដូចជា កិច្ចប្រជុំប្រចាំឆ្នាំ២០១៨ នៃវេទិកា BOAO ទ្វីបអាស៊ី និងកិច្ចប្រជុំកំពូលក្រុងឈីងតាវនៃអង្គការសហប្រតិបត្តិការសៀងហៃ ដែលមានការចូលរួមពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នានា ។ ឯកឧត្តម វ៉ាង យី សមាជិកក្រុមប្រឹក្សាកិច្ចការរដ្ឋចិនមានប្រសាសន៍ថា ឆ្នាំនេះគឺជា "ឆ្នាំសហប្រតិបត្តិការជាមួយប្រទេសកំពុងអភិវឌ្ឍន៍" សម្រាប់ការអភិវឌ្ឍទំនាក់ទំនងការទូតរបស់ប្រទេសចិន ។

ជាពិសេសខណៈពេលដែលប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនជួបនឹងបញ្ហាឱនភាពសន្តិភាព ឱនភាពនៃការអភិវឌ្ឍន៍ និងឱនភាពនៃការគ្រប់គ្រងប្រទេសចិនដែលជាប្រទេសកំពុងអភិវឌ្ឍន៍ធំជាងគេលើពិភពលោកនឹងរួមសហការយ៉ាងស្អិតល្មួតជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការជាយុទ្ធសាស្ត្រ រួមគ្នាកសាង "ខ្សែក្រវាត់មួយ និងផ្លូវមួយ" បង្កើតសហគមន៍រួមវាសនាមនុស្សជាតិ និងអភិវឌ្ឍន៍ទំនាក់ទំនងអន្តរជាតិបែបថ្មីជាដើម ដើម្បីជំរុញកិច្ចសហប្រតិបត្តិការឈ្នះ-ឈ្នះ និងរួមគ្នាធ្វើការអភិវឌ្ឍន៍ ៕

**(កាសែតប្រជាជនដេលីបោះពុម្ពផ្សាយនៅឯនាយសមុទ្រ)**